Health Consumer Alliance

# តើខ្ញុំគួរធ្វើបែបណា បើខ្ញុំទទួលបានវិក័យប័ត្រពេទ្យ?

បើអ្នកមិនមានធានារ៉ាប់រងសុខភាពទេ សូមសួរសំណួរដូចខាងក្រោម:

## សូមមើលវិក័យប័ត្រ។ តើអ្នកទទួលបានសេវាទាំងអស់នោះដែរឬទេ?

សូមហៅទៅកាន់អ្នកផ្តល់សេវាបើអ្នកមិនយល់អំពីសេវានៅលើវិក័យប័ត្រ។ អ្នកមានសិទ្ធិសួរព័ត៌មានលម្អិតនៅលើវិក័យប័ត្ររាល់សេវាទាំងអស់ដែលអ្នកប្រើប្រាស់ និងពេលអ្នកទៅជួបពួកគេ។ បើមានសេវាកម្មណាដែលអ្នកមិនបានប្រើប្រាស់ទេសូមស្នើសុំឱ្យអ្នកផ្តល់សេវាកម្មដកវាចេញ។

## តើអ្នកបានដាក់ពាក្យស្នើសុំសេវាសុខភាពឬនៅ?

អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការបង់ជំនួសទោះបីជាអ្នកធ្វើការក៏ដោយ។ បើអ្នកមានកូនពួកគេក៏អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការបង់ជំនួសដែរ ទោះបីជាអ្នកមិនបានទទួលក៏ដោយ។ មេឌីខល (Medi-Cal) អាចធ្វើការបង់ថ្លៃវិក័យប័ត្រដែលអ្នកទទួលបានក្នុងរយៈពេលបីខែមុនអ្នកប្រើសេវាមេឌីខល (Medi-Cal)។ ឧទាហរណ៍ បើអ្នកទៅមន្ទីរពេទ្យក្នុងខែមីនា អ្នកអាចស្នើសុំក្នុងខែមិថុនាដើម្បីទទួលបានការបង់ជំនួស។ ប៉ុន្តែសូមកុំរង់ចាំមកដាក់ពាក្យសុំឡើយ។ សូមសួររក "ការបង់ជំនួសឡើងវិញ" ពេលអ្នកដាក់ពាក្យស្នើសុំមកមេឌីខល (Medi-Cal) ឲ្យចេញថ្លៃវិក័យប័ត្រទាំងអស់ជំនួសអ្នក។ បន្ទាប់ពីដាក់ពាក្យស្នើសុំមេឌីខល (Medi-Cal) រួចហើយ សូមហៅលេខនៅលើវិក័យប័ត្រប្រាប់ថាមេឌីខល (Medi-Cal) របស់អ្នកកំពង់រង់ចាំបង់ប្រាក់ឱ្យ។ អ្នកអាចដាក់ពាក្យស្នើសុំមេឌីខល (Medi-Cal) នៅមន្ទីរពេទ្យ គ្លីនិក សហគមន៍ សាលាកូនរបស់អ្នក ការិយាល័យសេវាកម្មសង្គមក្នុងតំបន់ ឬតាមបណ្តាញ www.coveredca.com

## តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានកម្មវិធីសេវាកម្មគាំទ្រសុខភាពក្នុងងតំបន់ដែរឬទេ?

អ្នករស់នៅក្នុងតំបន់ដែលមិនមានវិធីសាស្ត្រផ្សេងទៀតដើម្បីចំណាយលើការថែទាំសុខភាព ពួកគេអាចទទួលបានសេវាកម្មនេះតាមរយៈកម្មវិធីសេវាសុខភាពក្នុងតំបន់។ បើអ្នកមិនធ្លាប់បានឮពីកម្មវិធីក្នុងតំបន់របស់អ្នកទេ សូមសួរទៅមន្ទីរពេទ្យ ឬគ្លីនិកដែលផ្ញើរវិក័យប័ត្រឱ្យអ្នក ថាតើហេតុអ្វីបានជាគេមិនបានពិនិត្យឲ្យអ្នកសម្រាប់កម្មវិធីសេវាសុខភាពក្នុងតំបន់។ អ្នកក៏អាចទំនាក់ទំនងទៅកាន់មន្ទីរសុខភាពក្នុងតំបន់អ្នកដែរ។

## តើអ្នកទើបតែបាត់បង់ធានារ៉ាប់រងនៅកន្លែងធ្វើការរបស់អ្នកឬ?

អ្នកអាចដាក់ពាក្យស្នើសុំមេឌីខល (Medi-Cal) ឬការគ្រប់ដណ្តប់រដ្ឋកាលីហ្វ័រញ៉ាតារយៈ www.coveredca.com ឬការិយាល័យសេវាកម្មសង្គមក្នុងតំបន់របស់អ្នក។ សម្រាប់ការគ្រប់ដណ្តប់រដ្ឋកាលីហ្វ័រញ៉ា អ្នកត្រូវតែដាក់ពាក្យស្នើក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបាត់បង់ធានារ៉ាប់រងរបស់អ្នក ឬក្នុងរយៈពេលនៃការបើកឱ្យចុះឈ្មោះប្រចាំឆ្នាំ។ បើអ្នកមិនអាចជួបជាមួយគ្រូពេទ្យបានទេអ្នកអាចធ្វើបានតាមរយៈមេឌីខល (Medi-Cal) ឬគ្រប់ដណ្តប់រដ្ឋកាលីហ្វ័រញ៉ា អ្នកអាចនឹងទទួលបានការគ្រប់ដណ្តប់ពីកូប្រា (COBRA)។ កូប្រា (COBRA) អនុញ្ញាតិឱ្យអ្នករក្សាធានារ៉ាប់រងរបស់អ្នកក្រោយពីអ្នកចាកចេញពីកន្លែងធ្វើការចាស់។ សូមពិនិត្យមើលជាមួយនិយោជក់ពីមុនរបស់អ្នកថាតើអ្នកនៅតែអាចជ្រើសរើសយកការគ្រប់ដណ្តប់កូប្រា (COBRA) បានដែរឬទេ។ អ្នកត្រូវតែបង់ប្រាក់ប្រចាំឆ្នាំសម្រាប់ធានារ៉ាប់រងសុខភាពទាំងមូលបើអ្នកអាចទទួលបានការគ្រប់ដណ្តប់ពីកូប្រា (COBRA)។

*(បន្ត)*

សម្រាប់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ និងប្រកបដោយទំនុកចិត្ត សូមទំនាក់ទំនងទៅកាន់ **មជ្ឈមណ្ឌលអ្នកប្រើប្រាស់សេវាសុខភាព** តាមរយៈលេខ **១-៨៨៨-៨០៤-៣៥៣៦**។ ចូលទៅកាន់ **www.healthconsumer.org** សម្រាប់ព័ត៌មានបន្ថែម។

## តើវិក័យប័ត្រចេញមកពីមន្ទីរពេទ្យ?

មន្ទីរពេទ្យ CA តម្រូវឱ្យផ្តល់ការថែទាំមនុស្សធម៌ ឬកម្មវិធីចុះតម្លៃសេវាដល់អ្នកជម្ងឺដែលមិនមានលទ្ធភាពដើម្បីបង់ថ្លៃវិក័យប័ត្រមន្ទីរពេទ្យ។ សូមសួរទៅមន្ត្រីចេញវិក័យប័ត្រដើម្បីទទួលបានពាក្យសុំ និងគោលនយោបាយ។ បើសំណើរត្រូវបានបដិសេធមិនផ្តល់ឱ្យអ្នកទេ អ្នកអាចរកឃើញតាមតាមរយៈវេបសាយ: www.syfphr.oshpd.ca.gov/FacilityList.aspx

## តើអ្នកមានបញ្ហានៅកន្លែងធ្វើការ ឬនៅពេលអ្នកធ្វើការអ្វីម្យ៉ាងនៅកន្លែងការងាររបស់អ្នក?

អ្នកគួរតែនិយាយទៅកាន់និយោជក់របស់អ្នកចំពោះសំណងដល់កម្មករនិយោជិក។ ការបង់សំណងដល់កម្មករនិយោជិកសម្រាប់ការថែសុខភាពដើម្បីព្យាបាលរបួសខណៈពេលដែលអ្នកធ្វើការងារសម្រាប់និយោជក់របស់អ្នក។ ក្រុមហ៊ុនអ្នកច្បាប់ដែលនៅក្នុងតំបន់ដែលអ្នករស់នៅអាចបញ្ជូនអ្នកទៅកាន់មេធាវីផ្នែកសំណងដល់និយោជិត។

ចូលទៅកាន់ www.calbar.ca.gov/Public/Need-Legal-Help/ ឬហៅទៅកាន់លេខ (៨៦៦) ៤៤២-២៥២៩ សម្រាប់ព័ត៌មានបន្ថែម។

## តើវិក័យប័ត្រថ្នាំពេទ្យស្តីអំពីគ្រោះថ្នាក់បណ្តាលមកពីនរណាម្នាក់?

និយាយទៅកាន់មេធាវីដែលធ្វើការលើករណី "គ្រោះថ្នាក់ផ្ទាល់ខ្លួន"។ អ្នកអាចមានសិទ្ធិទទួលបានសំណងពីអ្នកដែលបង្ករគ្រោះថ្នាក់ដល់អ្នក។ ក្រុមហ៊ុនអ្នកច្បាប់ដែលនៅក្នុងតំបន់ដែលអ្នករស់នៅអាចនឹងធ្វើការណែនាំអ្នកទៅមេធាវីឯកជន។ ចូលទៅកាន់ www.calbar.ca.gov/Public/Need-Legal-Help/ ឬហៅទៅកាន់ លេខ (៨៦៦) ៤៤២-២៥២៩ សម្រាប់ព័ត៌មានបន្ថែម។

**បើអ្នកត្រូវការជំនួយក្នុងការជ្រើសរើសនូវជម្រើសទាំងនេះ អ្នកអាចស្វែងរកជំនួយហៅទៅកាន់សម្ព័ន្ធអ្នកប្រើប្រាស់សេវាសុខភាពតាមរយៈលេខ (៨៨៨) ៨០៤-៣៥៣៦ ដោយឥតគិតថ្លៃ ព្រមទាំងទទួលបានជំនួយផ្នែកច្បាប់ប្រកបដោយទំនុកចិត្ត។**

សម្រាប់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ និងប្រកបដោយទំនុកចិត្ត សូមទំនាក់ទំនងទៅកាន់ **មជ្ឈមណ្ឌលអ្នកប្រើប្រាស់សេវាសុខភាព** តាមរយៈលេខ **១-៨៨៨-៨០៤-៣៥៣៦**។ ចូលទៅកាន់ **www.healthconsumer.org** សម្រាប់ព័ត៌មានបន្ថែម។